**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**តុលាការរដ្ឋប្បវេណី**

សំណុំរឿងរដ្ឋប្បវេណីលេខៈ ១១៨
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១
សាលក្រមរដ្ឋប្បវេណីលេខៈ ២៥(៣)/២៨២
ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ
នៅសាលសវនាការលេខៈ ២ក នៃសាលាដំបូងខេត្តសៀមរាប
បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ៈ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១
កាលបរិច្ឆេទប្រកាសសាលក្រមៈ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ឋានៈ ចៅក្រមសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ឋានៈ ក្រឡាបញ្ជី

**សហដើមចោទៈ**

ឈ្មោះ អ្នកអង្គម្ចាស់ [redacted] ប៉ាណារ៉ាស៊ីរីវុឌ្ឍ ([redacted] ប៉ាណារ៉ា) កើតឆ្នាំ១៩៤៨ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ [redacted]។

អ្នកតំណាងដោយអាណត្តិៈ លោកមេធាវី [redacted] អត្តលេខ ១៩១៦ មានការិយាល័យស្ថិតនៅអាគារ [redacted] និងលោកស្រី [redacted] អត្តលេខ ២២៧២T មានការិយាល័យស្ថិតនៅអគារលេខ [redacted]។

**សហចុងចម្លើយៈ**

១-ឈ្មោះ [redacted] ប៊ុណ្ណាង ([redacted] បណ្ណាង) ភេទប្រុស អាយុ៦៩ឆ្នាំ មានអាសយដ្ឋានស្ថិតនៅ [redacted]។

២-ឈ្មោះ [redacted]គង់ ភេទប្រុស អាយុ៦១ឆ្នាំ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ [redacted]

៣-ឈ្មោះ [redacted] សុខហៀង ភេទស្រី អាយុ៦៥ឆ្នាំ មានអាសយដ្ឋានស្ថិតនៅ [redacted]។

៤-ឈ្មោះ [redacted]ច័ន្ទតារា ភេទស្រី អាយុ៥៩ឆ្នាំ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ [redacted]។

៥-ឈ្មោះ [redacted] ភិរុន ភេទប្រុស អាយុ៤៩ឆ្នាំ មានអាសយដ្ឋានស្ថិតនៅផ្ទះ [redacted]

៦-ឈ្មោះ [redacted] ច័ន្ទវិទ្ធ ភេទប្រុស អាយុ៥២ឆ្នាំ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ [redacted]។

**ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទ**

១-សុំឲ្យតុលាការបញ្ជាក់អំពីអត្ថិភាពនៃកម្មសិទ្ធិរបស់ដើមចោទលើដីដែលមានដូចខាងក្រោមៈ

១-១-ដីទំហំ ១៩.០០០(ដប់ប្រាំបួនពាន់ )ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-២-ដីទំហំ ៤១.៣៦២(សែសិបមួយពាន់បីរយហុកសិបពីរ)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៣-ដីទំហំ ៤២.៥២៧(សែសិបពីរពាន់ប្រាំរយម្ភៃប្រាំពីរ)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៤-ដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៥-ដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៦-ដីទំហំ ៣៣.៥២៤(សាមសិបបីពាន់ប្រាំរយម្ភៃបួន)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

២-បង្គាប់ឲ្យសហចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីដែលមានទំហំ ២១២.៤១៣ (ពីររយដប់ពីរពាន់បួនរយដប់បី)ម៉ែត្រការ៉េ មានទីតាំងស្ថិតភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុដូចខាងក្រោមៈ

-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ លេខ ស.រ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៤០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

-ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។



Scanned with CamScanner

មកឲ្យដើមចោទ។

៣-សុំឲ្យសហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

**ខ-ដំណើររការរឿងក្ដី និងចំណុចវិវាទ**

**ខ-១-ការពន្យល់ត្រួសៗអំពីដំណើររឿងក្ដី**

កាលពីអំឡុងឆ្នាំ១៩៩៩ ដើមចោទបានទិញដីពីសហចុងចម្លើយដែលមានដូចខាងក្រោមៈ

១-ឈ្មោះ [redacted] ប៊ុណ្ណាង( [redacted] បណ្ណាង) នូវដីទំហំ ១៩.០០០(ដប់ប្រាំបួនពាន់)ម៉ែត្រការ៉េ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

២-ឈ្មោះ [redacted] គង់ នូវដីទំហំ ៤១.៣៦២(សែសិបមួយពាន់បីរយហុកសិបពីរ)ម៉ែត្រការ៉េ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

៣-ឈ្មោះ [redacted] សុខហៀង នូវដីទំហំ ៤២.៥២៧(សែសិបពីរពាន់ប្រាំរយម្ភៃប្រាំពីរ)ម៉ែត្រការ៉េ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

៤-ឈ្មោះ [redacted] ច័ន្ទតារា នូវដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

៥-ឈ្មោះ [redacted] ភិរុន នូវដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

៦-ឈ្មោះ [redacted] ច័ន្ទរិទ្ធិ នូវដីទំហំ ៣៣.៥២៤(សាមសិបបីពាន់ប្រាំរយម្ភៃបួន)ម៉ែត្រការ៉េ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

ដីទាំងអស់ខាងលើនេះ មានទីតាំងស្ថិតនៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

**ខ-២-អង្គហេតុដែលគ្មានវិវាទ**

ដើមចោទ និងសហចុងចម្លើយបានព្រមព្រៀងទិញលក់ដីដែលមានទីតាំងស្ថិតនៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដូចមាននៅក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ និងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ដោយមិនទាន់ចុះបញ្ជីផ្ទេរសិទ្ធិមកឲ្យដើមចោទទេ គឺធ្វើត្រឹមតែជាលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩ ចុះហត្ថលេខាដោយមេឃុំខ្នារសណ្ដាយ និងប្លង់ទីតាំងដីបែងចែកថ្មី ចុះហត្ថលេខាដោយអភិបាលស្រុករង រួមនឹងប្រធានភូមិបាលស្រុកបន្ទាយស្រី។

**ខ-៣-ចំណុចវិវាទ**

គ្មាន។

**ខ-៤-ការអះអាងរបស់ដើមចោទ**

លោកមេធាវី [redacted] និងលោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា:

ដើមចោទនៅតែរក្សាការទាមទារដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ រួមនឹងសេចក្តីថ្លែងការណ៍សម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ ទុកជាបានការដដែលដោយមូលហេតុថា៖ កាលពីអំឡុងឆ្នាំ១៩៩៩ ដើមចោទបានទិញដីពីសហចុងចម្លើយ៖

១-ឈ្មោះ [redacted] ប៊ុណ្ណាង ([redacted] បណ្ណាង) នូវដីទំហំ ដីទំហំ ១៩.០០០(ដប់ប្រាំបួនពាន់)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

២-ឈ្មោះ [redacted] គង់ នូវដីទំហំ ៤១.៣៦២(សែសិបមួយពាន់បីរយហុកសិបពីរ)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

៣-ឈ្មោះ [redacted] សុខហៀង នូវដីទំហំ ៤២.៥២៧(សែសិបពីរពាន់ប្រាំរយម្ភៃប្រាំពីរ)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិ សណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

៤-ឈ្មោះ [redacted] ច័ន្ទតារា នូវដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

៥-ឈ្មោះ [redacted] ភិរុន នូវដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

៦-ឈ្មោះ [redacted] ច័ន្ទដ៏រិទ្ធិ នូវដីទំហំ ៣៣.៥២៤(សាមសិបបីពាន់ប្រាំរយម្ភៃបួន)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

ដែលដីសរុបទាំងអស់មានចំនួន ២១២.៤១៣(ពីររយដប់ពីរពាន់បួនរយដប់បី)ម៉ែត្រការ៉េ ដោយបានធ្វើជាលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩ មានចុះហត្ថលេខាដោយលោក [redacted] ជាមេឃុំខ្នារសណ្តាយ និងមានប្លង់ទីតាំងដីបែងចែកថ្មី ចុះឆ្នាំ១៩៩៦ ដែលចុះហត្ថលេខាដោយលោក [redacted] អភិបាលស្រុករង រួមនឹងប្រធានភូមិបាលស្រុកបន្ទាយស្រី ព្រមទាំងប្រគល់ឯកសារច្បាប់ដើម(ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ)ទាំង០៦ច្បាប់ មកឲ្យដើមចោទ។

ក្រោយពីបានទិញដីរួចរាល់ហើយ ដើមចោទបានជួលឈ្មោះ [redacted] សារុន ដែលជាអ្នកធ្វើការជាមួយ និងជាអ្នកមានដីនៅទីតាំងនោះ ឲ្យមកដាក់បង្គោលស៊ីម៉ងត៍តាមព្រំដីចំនួន០៨(ប្រាំបី)ដើម ព័ទ្ធជុំវិញដី ដោយក្នុងបង្គោលមួយដើមតម្លៃ ២៥$(ម្ភៃប្រាំដុល្លារអាមេរិក) បូករួមទាំងពលកម្ម សរុបទាំងអស់ចំណាយប្រាក់អស់ ៣០០$(បីរយដុល្លារអាមេរិក) និងបានដាំស្វាយចន្ទីជាច្រើនដើមនៅលើដីនោះទៀតផង។ ចំពោះការ

រៀបត្រាំដីនេះ គឺឈ្មោះ [redacted] សារុន បានចុះហត្ថលេខាបញ្ជាក់ផងដែរនៅក្នុងប្លង់ទីតាំងដីបែងចែកថ្មី ចុះឆ្នាំ១៩៩៦។

បន្ទាប់ពីរៀបចំព្រំ និងដាំដំណាំរួច ដើមចោទតែងតែឡើងចុះទៅមើលដីជាប្រចាំមិនបានទុកចោលនោះទេ។ ប៉ុន្តែនៅចន្លោះឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ដោយសារតែដើមចោទមានបញ្ហាសុខភាព ត្រូវទៅព្យាបាលជម្ងឺរួមទាំងវះកាត់ខួលក្បាលនៅប្រទេសបារាំងមួយរយៈ ហើយរហូតមកទល់បច្ចុប្បន្ននេះក៏មានការពិបាកក្នុងការធ្វើដំណើរឡើងចុះទៅមើលថែចំការឲ្យបានជាប់លាប់នោះទេ។ ទើបថ្មីៗនេះ ដើមចោទបានលក់ដីខាងលើនេះ តែត្រូវបានមន្ត្រីជំនាញសុរិយោដីថាមិនអាចផ្ទេរកម្មសិទ្ធិបានទេ ដោយសារតែឈ្មោះក្នុងប្លង់នឹង ទាំងអស់នៅជាឈ្មោះរបស់ម្ចាស់ដីដើម(សហចុងចម្លើយ)នៅឡើយ ហើយចាំបាច់តម្រូវឲ្យសហចុងចម្លើយធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិដោយស្របច្បាប់មកឲ្យដើមចោទជាមុនសិន។ ចាប់តាំងពីទិញដីខាងលើនេះ សហចុងចម្លើយមិនដែលបានធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិដោយស្របច្បាប់មកដើមចោទ និងមិនអើពើអំពីកាតព្វកិច្ចផ្ទេរសិទ្ធិរបស់ខ្លួនមកឲ្យដើមចោទនោះទេ។

ចំពោះប្រាក់ប្រដាប់ក្តី ដើមចោទទាមទារឲ្យសហចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី និងប្រាក់បង់ពន្ធផ្សេងៗ ដោយសារតែសហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចក្នុងការធ្វើផ្ទេរកម្មសិទ្ធិមកឲ្យដើមចោទទើបឈានទៅដល់ការដាក់ពាក្យបណ្តឹង ហើយការដាក់ពាក្យបណ្តឹងនេះ គឺទាមទារឲ្យមានការបង់ពន្ធ ហេតុនេះការទទួលបន្ទុកបង់ពន្ធត្រូវតែជាបន្ទុករបស់ភាគីសហចុងចម្លើយ។

**ខ-៥-ការអះអាងរបស់សហចុងចម្លើយ**

សហចុងចម្លើយឈ្មោះ [redacted] ប៊ុណ្ណាង ([redacted] បណ្ណាង), ឈ្មោះ [redacted] គង់, ឈ្មោះ [redacted] សុខហៀង, ឈ្មោះ [redacted] ច័ន្ទតារា, ឈ្មោះ [redacted] ភិរុន និងឈ្មោះ [redacted] ច័ន្ទដ៏រិទ្ធិ យើងបានធ្វើការកោះហៅតាមរយៈ ដីកាកោះចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ ភ្ជាប់ជាមួយនឹងលិខិតជូនដំណឹង សេចក្តីថ្លែងការណ៍របស់ដើមចោទ និងឯកសារផ្សេងៗឲ្យទៅសហចុងចម្លើយត្រឹមត្រូវហើយ តាមរបៀបបញ្ជូនតាមការផ្សាយជាសារជាណៈ តាមរយៈការចុះក្នុងសារព័ត៌នគរធំ, បិតប្រកាសនៅបញ្ជារព័ត៌មានរបស់សាលាដំបូងខេត្តសៀមរាប, បិតនៅទីស្នាក់ការសាលាសង្កាត់បឹងរាំង, សាលាសង្កាត់បឹងកេងកងទី១ ដែលជាទីលំនៅរបស់ហចុងចម្លើយ ដើម្បីចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែសហចុងចម្លើយ នៅតែអវត្តមាន។

## សំអាងហេតុ

ពាក្យបណ្តឹងអង្គសេចក្តី ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់ដើមចោទឈ្មោះ **អ្នកអង្គម្ចាស់ [redacted] ប៉ាណារ៉ាស៊ីវ៉ុឌ្ឍ([redacted] ស៊ីវ៉ុធ ប៉ាណារ៉ា)** តុលាការអាចលើកយកមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានតាមបញ្ញត្តិមាត្រា ៩ និងមាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិដើមចោទ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ រួមនិងការពិនិត្យភស្តុតាងជាឯកសារដែលមានក្នុងសំណុំរឿងឃើញថា៖

**ក-ការវិនិច្ឆ័យចំពោះការទាមទាររបស់ដើមចោទ**

១-សុំឲ្យតុលាការបញ្ជាក់អំពីអត្ថិភាពនៃកម្មសិទ្ធិរបស់ដើមចោទលើដី (អត្តសញ្ញាណនៃដីដូចមានបញ្ជាក់ក្នុងកម្មវត្ថុនៃការទាមទារ)

១-១-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ និងតាមការពិនិត្យភស្តុតាងជាឯកសារ មានប្លង់ទីតាំងដីបែងចែកថ្មី ចុះឆ្នាំ១៩៩៦, ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ឃើញថាសហចុងចម្លើយបានកាន់កាប់អចលនវត្ថុនេះ តាមអានុភាពនៃច្បាប់ភូមិបាល ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩២ ហើយបានចុះបញ្ជីសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចេញដោយប្រធាននាយកដ្ឋានសុរិយោដី ដោយមានសហចុងចម្លើយឈ្មោះ [redacted] ប៊ុនណ្ណាង([redacted] បណ្ណាង) មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ឈ្មោះ [redacted] គង់ មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ឈ្មោះ [redacted] សុខហៀង មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ,ឈ្មោះ [redacted] ច័ន្ទតារា មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ,ឈ្មោះ [redacted] ភិរុន មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ និងឈ្មោះ [redacted] ច័ន្ទរិទ្ធ មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨ ដែលដីទាំងអស់នេះមានទីតាំងស្ថិតនៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ម្យ៉ាងទៀតបើតាមលិខិតលេខ ២៥០ ដនសស.សរ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តសៀមរាប បានបញ្ជាក់ថា ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ(០៦ប័ណ្ណ)របស់សហចុងចម្លើយ បានចុះបញ្ជីត្រឹមត្រូវក្នុងសៀវភៅគល់បញ្ជី ស្របតាមនីតិវិធីដោយពុំមានជាប់បន្ទុក និងដីការបស់តុលាការទេ។

១-២-តាមការពិនិត្យភស្តុតាងជាឯកសារមានលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩ ឃើញថា សហចុងចម្លើយបានផ្ទេរនូវសិទ្ធិកាន់កាប់ដែលខ្លួនមានរៀងៗខ្លួន ដែលផ្អែកតាមប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ខាងលើនេះឲ្យទៅដើមចោទ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩ ។

១-៣-តាមចំណុចទី១-១ និងទី១-២ ខាងលើនេះ ឃើញថាសហចុងចម្លើយបានធ្វើសកម្មភាព ក្នុងការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុឲ្យដើមចោទ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩ អនុលោមតាមច្បាប់ភូមិបាល ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩២ ដែលមានចែងក្នុងមាត្រា ៦០ និងមាត្រា ៧៣ ហើយដើមចោទបានបន្តកាន់កាប់អចលនវត្ថុនេះរហូតមកដល់បច្ចុប្បន្ន ។

១-៤-តាមមាត្រា ១៤(ភោគៈ) នៃច្បាប់ស្តីពីអនុវត្តក្រមរដ្ឋប្បវេណី ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ និងមាត្រា ២៤២(ការកាន់កាប់ភោគីអចលនវត្ថុដែលមានប័ណ្ណសិទ្ធិកាន់កាប់) នៃក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ បានការពារអ្នកកាន់កាប់ពិសេសអំពីអចលនវត្ថុ ចំពោះដីមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ក្រៅពីត្រូវអនុលោមតាមបញ្ញត្តិច្បាប់ភូមិបាល ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ និងមាត្រា ២៤២ នៃក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ត្រូវយកមកអនុវត្តចំពោះដីនោះ ដោយ



Scanned with CamScanner

ចាត់ទុកថាភោគៈដែលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនោះ ត្រូវបានចេញជាកម្មសិទ្ធិ។ ផ្អែកតាមបទប្បញ្ញត្តិនេះ ឃើញថាប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដែលសហចុងចម្លើយបានផ្ទេរសិទ្ធិកាន់កាប់ឲ្យ ដើមចោទ ហើយដើមចោទបានកំពុងតែកាន់កាប់នេះបានបន្តសុពលភាព ដោយអនុលោមតាមច្បាប់ស្តីពីអនុវត្តក្រមរដ្ឋប្បវេណី និងក្រមរដ្ឋប្បវេណី ។

១-៥-តាមចំណុចទី១-៣ និងទី១-៤ ខាងលើនេះឃើញថា ដើមចោទមានអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិនូវដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៤០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨, ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

ហេតុដូច្នេះ តុលាការគប្បីសម្រេចបញ្ជាក់ថា ដើមចោទមានអត្ថិភាពនៃកម្មសិទ្ធិលើដី(អត្តសញ្ញាណនៃដីដូចមានបញ្ជាក់ក្នុងកម្មវត្ថុនៃការទាមទារ)។

**២-បង្គាប់ឲ្យសហចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីទ្រព្យសម្បត្តិ (អត្តសញ្ញាណនៃដីដូចមានបញ្ជាក់ក្នុងកម្មវត្ថុនៃការទាមទារ)**

២-១-តាមការពិនិត្យកស្តុតាងជាឯកសារមានលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩ ឃើញថា សហចុងចម្លើយបានផ្ទេរនូវសិទ្ធិកាន់កាប់ដែលខ្លួនមានរៀងៗខ្លួន ដែលផ្អែកតាមប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ខាងលើនេះ ឲ្យទៅដើមចោទ កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៩ ប៉ុន្តែសហចុងចម្លើយនៅមិនទាន់បានចុះបញ្ជីផ្ទេរសិទ្ធិឲ្យមកដើមចោទឡើយ ហើយដើមចោទបានទាមទារឲ្យសហចុងចម្លើយធ្វើសកម្មភាពនៃការចុះបញ្ជីឲ្យមកដើមចោទ។

២-២-សហចុងចម្លើយបានអវត្តមានគ្រប់នីតិវិធីរបស់តុលាការ ហើយតុលាការបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ តាមរយៈការចុះក្នុងសារព័ត៌មាននគរធំ បិតប្រកាសនៅបញ្ជរព័ត៌មានរបស់សាលាដំបូងខេត្តសៀមរាប និងបិទប្រកាសនៅទីស្នាក់ការសាលាសង្កាត់បឹងរាំង ដែលជាទីលំនៅរបស់សហចុងចម្លើយនូវដីកាកោះហៅសហចុងចម្លើយ ដើម្បីចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ លិខិតជូនដំណឹង សេចក្តីថ្លែងការណ៍របស់ដើមចោទ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ឲ្យទៅសហចុងចម្លើយ ស្របតាមមាត្រា ២០២ និងមាត្រា ២៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ យោងតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការណ៍ដែលសហចុងចម្លើយមិនបានបង្ហាញខ្លួនក្នុងនិតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការចាត់ទុកថា សហចុងចម្លើយសារភាពចំពោះអង្គហេតុដែលដើមចោទបានលើកឡើង ហើយតុលាការទទួលស្គាល់តាមការអះអាងរបស់ដើមចោទ ដូច្នេះ សហចុងចម្លើយមានករណីក្នុងការធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យដើមចោទ ។

**៣-ដើមចោទប្តឹងទាមទារឲ្យសហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី**

ដោយសារសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចផ្ទេរសិទ្ធិ និងជាអ្នកមានកំហុស ដោយយោងតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី បន្ទុកនៃប្រាក់ប្រដាប់ក្តីជារបស់ភាគីចាញ់ក្តី។



Scanned with CamScanner

## សេចក្តីសម្រេចបញ្ចប់

១-បញ្ជាក់ថា ដើមចោទមានអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិនូវដីដែលមានដូចខាងក្រោមៈ

១-១-ដីទំហំ ១៩.០០០(ដប់ប្រាំបួនពាន់ )ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-២-ដីទំហំ ៤១.៣៦២(សែសិបមួយពាន់បីរយហុកសិបពីរ)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៣-ដីទំហំ ៤២.៥២៧(សែសិបពីរពាន់ប្រាំរយម្ភៃប្រាំពីរ)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៤-ដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៥-ដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៦-ដីទំហំ ៣៣.៥២៤(សាមសិបបីពាន់ប្រាំរយម្ភៃបួន)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

២-បង្គាប់ឲ្យសហចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលលើដីដែលមានដូចខាងក្រោមៈ

១-១-ដីទំហំ ១៩.០០០(ដប់ប្រាំបួនពាន់ )ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨៥ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-២-ដីទំហំ ៤១.៣៦២(សែសិបមួយពាន់បីរយហុកសិបពីរ)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៣-ដីទំហំ ៤២.៥២៧(សែសិបពីរពាន់ប្រាំរយម្ភៃប្រាំពីរ)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៩៩ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៤-ដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។



Scanned with CamScanner

១-៥-ដីទំហំ ៣៨.០០០(សាមសិបប្រាំបីពាន់)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៣៨១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

១-៦-ដីទំហំ ៣៣.៥២៤(សាមសិបបីពាន់ប្រាំរយម្ភៃបួន)ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ស.រ ០០៣៤០១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៨។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១។ ក្នុងករណីភាគីមិនសុខចិត្តនិងសាលក្រមនេះអាចប្ដឹងឧទ្ធរណ៍ ក្នុងអំឡុងពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃទទួលការបញ្ជូនលិខិតសាលក្រមនេះ៥

**ចៅក្រម**

ហត្ថលេខា និង ត្រា: [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១០រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

សៀមរាប ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១

**បានឃើញ**

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពី

ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប, ថ្ងៃទី០៦ ខែ..... ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]